**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជននៅក្រុងនគរធំ និងឃុំពាក់ស្នែង នៃស្រុកអង្គរធំ ខេត្តសៀមរាប

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



https://www.moj.gov.kh/kh/law-regular

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្ដីពីការបង្កើតមូលនិធិជាតិជំនួយសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៣៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីប្រាក់ឧបត្ថម្ភ វិធាន នីតិវិធី និងយន្តការគ្រប់គ្រងការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង នៃស្រុកអង្គរធំ ខេត្តសៀមរាប ដើម្បីលើកកម្ពស់បរិស្ថាននៃការរស់នៅឱ្យកាន់តែប្រសើរឡើង។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រួសារដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដីនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ក្រោមការរៀបចំរបស់គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងអភិវឌ្ឍទីប្រជុំជនរុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប ព្រមទាំងមានបណ្ណសមធម៌មានសុពលភាព។

## ជំពូកទី២
## ប្រាក់ឧបត្ថម្ភ លក្ខខណ្ឌនៃការទទួលផល គោលការណ៍ និងរយៈពេលនៃការអនុវត្ត

**មាត្រា៣ .-**

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីនេះ គ្រួសារនីមួយៗត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- បានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដីនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ក្រោមការរៀបចំរបស់គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងអភិវឌ្ឍទីប្រជុំជនរុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប និង
- មានបណ្ណសមធម៌មានសុពលភាព។



https://www.moj.gov.kh/kh/law-regular

**មាត្រា៤ .-**

សម្រាប់រយៈពេល ៣ (បី) ខែ គិតចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ២០២៤ ក្នុងដំណាក់កាលអន្តរកាល មុននឹងចាប់ផ្តើមអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង នៃស្រុកអង្គរធំ ខេត្តសៀមរាប គ្រួសារដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដីនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង និងមានបណ្ណសមធម៌មានសុពលភាព ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៤០ ០០០ (សែសិបពាន់) រៀល សម្រាប់សមាជិកគ្រួសារម្នាក់ៗ។

**មាត្រា៥ .-**

កម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង នៃស្រុកអង្គរធំ ខេត្តសៀមរាប ត្រូវចាប់ផ្តើមអនុវត្តចាប់ពីខែមេសា ឆ្នាំ២០២៤ តាមអត្រាខាងក្រោម៖

| ល.រ | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | អត្រាប្រាក់ឧបត្ថម្ភក្នុងមួយខែ |
|---|---|---|
| ១ | គ្រួសារ | ៨៦ ០០០ រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ៤០ ០០០ រៀល |
| ៣ | កុមារអាយុពី ០-៥ ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០ រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ១២ ០០០ រៀល |
| ៥ | មនុស្សចាស់ចាប់ពី ៦០ ឆ្នាំឡើងក្នុងម្នាក់ៗ | ១២ ០០០ រៀល |
| ៦ | គ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ១២ ០០០ រៀល |

**មាត្រា៦ .-**

គ្រួសារនីមួយៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ សម្រាប់រយៈពេល ៣៦ខែ ដោយកាលបរិច្ឆេទចាប់ផ្តើមត្រូវអនុវត្ត ដូចខាងក្រោម៖

- គ្រួសារដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដី ត្រូវទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី ចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។
- គ្រួសារថ្មីដែលនឹងស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដីនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ត្រូវទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី ដូចមានចែងក្នុងមាត្រា៤ និង៥ នៃអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃទទួលបានបណ្ណសមធម៌ តទៅ ស្របតាមគោលការណ៍ដែលមានជាធរមាន។

បន្ទាប់ពីរយៈពេល ៣៦(សាមសិបប្រាំមួយ)ខែ គិតចាប់ពីថ្ងៃទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី ក្រសួងផែនការ តាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នឹងធ្វើការវាយតម្លៃគ្រួសារទាំង ២ប្រភេទខាងលើឡើងវិញ។ ក្នុងករណីពិនិត្យឃើញថានៅមានការលំបាក គ្រួសារនោះនឹងបន្តទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី។

គ្រួសារដែលមិនបានតាំងលំនៅឋានជាក់ស្តែងនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង និងគ្រួសារដែលត្រូវបានវាយតម្លៃឃើញថាមិនមានការលំបាក នឹងទទួលបានតែអត្ថប្រយោជន៍ផ្សេងៗពី



https://www.moj.gov.kh/kh/law-regular

កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ស្របតាមសុពលភាពបណ្ណសមធម៌ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧ .-**

ក្នុងអំឡុងពេលអនុវត្តកម្មវិធី គ្រួសារដែលបានលក់ ឬផ្ទេរលំនៅឋានបន្តទៅឱ្យអ្នកដទៃក្រៅពីករណីផ្ទេរមរតកឱ្យសមាជិកគ្រួសារដែលមានក្នុងបណ្ណសមធម៌ នឹងមិនបន្តទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី ឬត្រូវបានចាកចេញពីកម្មវិធីដោយស្វ័យប្រវត្តិ។

អ្នកទិញបន្ត មិនត្រូវទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីនោះទេ។

**មាត្រា៨ .-**

ការបើកផ្តល់សាច់ប្រាក់ក្រោមកម្មវិធីស្តារជីវភាពឡើងវិញនេះ ត្រូវអនុវត្តដោយមូលនិធិជាតិជំនួយសង្គម តាមរយៈយន្តការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភដែលមានស្រាប់។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ និងអនុវត្តកម្មវិធី

**មាត្រា៩ .-**

កម្មវិធីស្តារជីវភាពឡើងវិញនេះ ត្រូវដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមឱវាទ និងដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមទទួលបន្ទុកវាយតម្លៃការអនុវត្តកម្មវិធីនេះ ដោយមានកិច្ចសហការពីក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

**មាត្រា១០ .-**

ក្រសួងផែនការទទួលបន្ទុកផ្តល់ទិន្នន័យគ្រួសារដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋាន និងទទួលបានក្បាលដីនៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង និងមានបណ្ណសមធម៌មានសុពលភាព ជូនមូលនិធិជាតិជំនួយសង្គម។ ក្រសួងផែនការទទួលបន្ទុកវាយតម្លៃស្ថានភាពជីវភាពគ្រួសារដាក់ស្តែងឡើងវិញ និងចេញលិខិតបញ្ជាក់អំពីស្ថានភាពគ្រួសារ ស្របតាមមាត្រា៦ នៃអនុក្រឹត្យនេះ។

**មាត្រា១១ .-**

មូលនិធិជាតិជំនួយសង្គមទទួលបន្ទុកជាប្រតិបត្តិករ ក្នុងការគ្រប់គ្រង និងចាត់ចែងការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភជូនគ្រួសារដែលបានស្ម័គ្រចិត្តផ្លាស់ប្តូរលំនៅឋានទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ដែលមានបណ្ណសមធម៌មានសុពលភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ មូលនិធិជាតិជំនួយសង្គម ត្រូវរៀបចំគម្រោងថវិកាសម្រាប់ការអនុវត្តការបើកផ្តល់ បញ្ជូនទិន្នន័យប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារគោលដៅនីមួយៗទៅស្ថាប័នបើកផ្តល់ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភ អប់រំផ្សព្វផ្សាយអំពីកម្មវិធី និងការបើកផ្តល់ដល់មន្ត្រីពាក់ព័ន្ធ និងគ្រួសារគោលដៅ និងទទួលបន្ទុកការងារពាក់ព័ន្ធសំខាន់ៗដទៃទៀត ក្រោមកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។



https://www.moj.gov.kh/kh/law-regular

**មាត្រា១២ .-**

រដ្ឋបាលខេត្តសៀមរាប និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការ និងគាំទ្រដល់ការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ, ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ, ការផ្តល់ព័ត៌មាន និងអប់រំផ្សព្វផ្សាយអំពីកម្មវិធី, និងការងារពាក់ព័ន្ធដទៃទៀត ដោយមានការសម្របសម្រួល និងគាំទ្រ ដោយក្រសួងមហាផ្ទៃ តាមការចាំបាច់។

## ជំពូកទី៤
## ថវិកាអនុវត្តកម្មវិធី និងប្រតិបត្តិការកម្មវិធី

**មាត្រា១៣ .-**

រាល់ចំណាយលើការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញនេះ ត្រូវហិរញ្ញប្បទានដោយថវិកាជាតិ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម ស្របតាមនីតិវិធីជាធរមាន។

**មាត្រា១៤ .-**

នីតិវិធីអនុវត្តថវិកា ការផ្តល់របាយការណ៍ និងការត្រួតពិនិត្យការអនុវត្តកម្មវិធី ត្រូវអនុវត្តស្របតាម ស្មារតីនៃអនុក្រឹត្យលេខ ៣៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីជាតិ ជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

**មាត្រា១៥ .-**

ការដោះស្រាយវិវាទ ឬបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញនេះ ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីដែលបានកំណត់ក្នុងការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

## ជំពូកទី៥
## ករណីប្រធានសក្តិ

**មាត្រា១៦ .-**

ក្នុងករណីប្រធានសក្តិ ឬមានវិបត្តិធ្ងន់ធ្ងរកើតឡើង មូលនិធិជាតិជំនួយសង្គម ត្រូវស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គមដោយលើកជាជម្រើសសមស្រប ដើម្បីឱ្យអ្នកទទួលផលទទួលបានប្រាក់ឧបត្ថម្ភពីការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular